ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មានរួម
# ពិធីចុះអនុស្សរណៈនៃការយោគយល់ស្តីពី
# "ការជំរុញការចាប់យកឌីជីថលរបស់ធុរកិច្ចនៅកម្ពុជា"
# រវាង
# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល,
# សម្ព័ន្ធសមាគមសហគ្រាសធុនតូច និង មធ្យមកម្ពុជា,
# សមាគមសហគ្រិនវ័យក្មេងកម្ពុជា, និង
# សមាគមសហគ្រិនស្ត្រីកម្ពុជា

នាព្រឹកថ្ងៃ ពុធ ទី ២៦ ខែ មីនា ឆ្នាំ ២០២៥, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.), **ឧកញ៉ា តែ តាំងប៉** ប្រធានសម្ព័ន្ធសមាគមសហគ្រាសធុនតូច និង មធ្យមកម្ពុជា, **លោកជំទាវ ចាន់ តារី** ប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា, និង **ឧកញ៉ា ម៉ិច បូឡែន** ប្រធានសមាគមសហគ្រិនវ័យក្មេងកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពី "**ការជំរុញការចាប់យកឌីជីថលរបស់ធុរកិច្ចនៅកម្ពុជា**"។

ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួង តំណាងសមាគម និង ដៃគូអភិវឌ្ឍនានា សរុបប្រមាណ ៥០ រូប, អនុស្សរណៈនៃការយោគយល់នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងជំរុញកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និង វិស័យឯកជន ដើម្បីពង្រីកវិសាលភាពនៃការផ្សព្វផ្សាយចំណេះដឹង និង ជំនាញបច្ចេកវិទ្យាថ្មីៗដល់ធុរជន ម្ចាស់អាជីវកម្ម និង សហគ្រាសនៅកម្ពុជា សំដៅកសាងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចឌីជីថលនៅកម្ពុជាឱ្យកាន់តែមានភាពរស់រវើក។ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** បានគូសបញ្ជាក់ពីការវិវឌ្ឍយ៉ាងឆាប់រហ័សរបស់បច្ចេកវិទ្យាឌីជីថល និង ធុរកិច្ចនៅកម្ពុជា ព្រមទាំងបានលើកទឹកចិត្តឱ្យសហគ្រាសគ្រប់កម្រិត និង គ្រប់វិស័យ ព្រមទាំងសហគ្រិនទាំងអស់ ប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីធានាបាននូវចីរភាពអាជីវកម្ម បង្កើនផលិតភាព ប្រសិទ្ធភាពសេដ្ឋកិច្ច និង ភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងតំបន់ និង សកលលោក។ នៅក្នុងពិធីនេះដែរ **ឧកញ៉ា តែ តាំងប៉** ប្រធានសម្ព័ន្ធសមាគមសហគ្រាសធុនតូច និង មធ្យមកម្ពុជា បានបង្ហាញពី ការជឿជាក់ថា

ការចុះអនុស្សរណៈនៃការយោគយល់នេះនឹងផ្តល់នូវកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធ ក្នុងការរួមចំណែកលើការជំរុញសេដ្ឋកិច្ចឌីជីថល ជាពិសេស លើវិស័យសហគ្រាសធុនតូច និង មធ្យមនៅកម្ពុជា។ ទន្ទឹមនេះ **លោកជំទាវ ចាន់ នារី** ប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា បានគូសបញ្ជាក់ពីការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល និង លើកទឹកចិត្តឱ្យសហគ្រិនស្ត្រី ព្រមទាំងសហគ្រិនគ្រប់កម្រិតឱ្យចាប់យកបច្ចេកវិទ្យាឌីជីថលក្នុងការគ្រប់គ្រងអាជីវកម្ម។ **ឧកញ៉ា ម៉ិច ម៉ូឡែន** ប្រធានសមាគមសហគ្រិនវ័យក្មេង បានលើកឡើងស្រដៀងគ្នាថា ការចុះអនុស្សរណៈនៃការយោគយល់នេះនឹងរួមចំណែកក្នុងកិច្ចសហការ ជាពិសេស គាំទ្រដល់សហគ្រាស ម្ចាស់-អាជីវកម្ម និង ធុរកិច្ចថ្មីៗ ឱ្យកាន់តែរីកចម្រើន និង មានការប្រកួតប្រជែងខ្ពស់។

កិច្ចសហប្រតិបត្តិការ រវាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល និង សម្ព័ន្ធសមាគមសហគ្រាសធុនតូច និង មធ្យមកម្ពុជា, សមាគមសហគ្រិនវ័យក្មេង, និង សមាគមសហគ្រិនវ័យក្មេងកម្ពុជា នាពេលនេះ គឺជាការបើកទំព័រថ្មីមួយទៀត ដែលអនុញ្ញាតឱ្យរដ្ឋាភិបាល និង វិស័យឯកជនបង្កើតជាគំរូនៃកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និង វិស័យឯកជន តាមរយៈការចែករំលែកនូវចំណេះដឹង បទពិសោធន៍ ឧត្តមានុវត្តន៍ និង ការបណ្តុះបណ្តាលពាក់ព័ន្ធនឹងធុរកិច្ចឌីជីថល និង ជំរុញការប្រើប្រាស់បច្ចេកវិទ្យាគាំទ្រ និង បច្ចេកវិទ្យាដែលកំពុងលេចឡើងថ្មីៗ ដែលជាគន្លឹះគាំទ្រដល់សេដ្ឋកិច្ច និង សង្គមឌីជីថលនៅកម្ពុជា។ តាមរយៈកិច្ចសហប្រតិបត្តិការនេះ អគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ. សហការជាមួយសមាគមទាំងបី នឹងនាំមកនូវគំនិតផ្តួចផ្តើម និង កម្មវិធីជាច្រើន សំដៅគាំទ្រដល់ការចាប់យកឌីជីថលរបស់ធុរកិច្ច។

សម្រាប់ព័ត៌មានអំពីកម្មវិធីពាក់ព័ន្ធនឹងការចាប់យកឌីជីថលរបស់ធុរកិច្ចនៅកម្ពុជា សូមសាធារណជនទាំងអស់មេត្តាតាមដានលើគេហទំព័រ និង គ្រប់បណ្តាញសង្គមរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល និង សម្ព័ន្ធសមាគមសហគ្រាសធុនតូច និង មធ្យមកម្ពុជា, សមាគមសហគ្រិនវ័យក្មេងកម្ពុជា និង សមាគមសហគ្រិនស្ត្រីកម្ពុជា។

**គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល**

- គេហទំព័រផ្លូវការ៖ https://digitaleconomy.gov.kh
- គេហទំព័រហ្វេកប៊ុក៖គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល - គសធឌ

**សមាគមសហគ្រាសធុនតូច និង មធ្យមកម្ពុជា**

- គេហទំព័រហ្វេកប៊ុក៖ Federation of Associations for SMEs of Cambodia - FASMEC

**សមាគមសហគ្រិនវ័យក្មេងកម្ពុជា**

- គេហទំព័រផ្លូវការ៖ https://www.yeacambodia.org
- គេហទំព័រហ្វេកប៊ុក៖ YEAC - Young Entrepreneurs Association of Cambodia

**សមាគមសហគ្រិនស្ត្រីកម្ពុជា**

- គេហទំព័រផ្លូវការ៖ https://cweacambodia.org
- គេហទំព័រហ្វេកប៊ុក៖ CWEA - Cambodia Women Entrepreneurs Association